**រាជរដ្ឋាភិបាល**
**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**
**Council for the Development of Cambodia**
**គណៈកម្មាធិការវិនិយោគកម្ពុជា**
**Cambodian Investment Board**

**ព្រះរាជាណាចក្រកម្ពុជា**
**Kingdom of Cambodia**
**ជាតិ សាសនា ព្រះមហាក្សត្រ**
***Nation- Religion- King***

ថ្ងៃព្រហស្បតិ៍ ១២កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស ២៥៧០
រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែឧសភា ឆ្នាំ ២០២៦

លេខៈ ១៩៩៩/២៦ គ.វ.ក

# សេចក្តីណែនាំ
# ស្តីពី
# ការអនុវត្តទុនវិនិយោគជាក់ស្តែងឱ្យបានស្មើ ឬលើសទុនអប្បបរមា សម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងវិស័យកម្មន្តសាល

ដើម្បីជានាអនុលោមភាពនៃការអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ.) ក្នុងវិស័យកម្មន្តសាល ស្របតាមស្មារតីនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.វ.ក./ក.អ.ក.) សូមធ្វើការណែនាំដូចខាងក្រោមៈ

គ.ល.គ. ក្នុងវិស័យកម្មន្តសាល ត្រូវអនុវត្តទុនវិនិយោគជាក់ស្តែងឱ្យបានស្មើ ឬលើសទុនអប្បបរមា ដែលមានចែងក្នុងបញ្ជីអវិជ្ជមាននៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលមិនលើសពី ៣ (បី) ឆ្នាំ។ រយៈពេល៣ឆ្នាំនេះ ត្រូវរាប់ចាប់ពីៈ

- កាលបរិច្ឆេទនៃវិញ្ញាបនបត្រចុះបញ្ជី សម្រាប់ គ.ល.គ. ដែលត្រូវបានចុះបញ្ជីក្រោយការចេញសេចក្តីណែនាំនេះ និង
- កាលបរិច្ឆេទនៃសេចក្តីណែនាំនេះ សម្រាប់ គ.ល.គ. ដែលត្រូវបានចុះបញ្ជីមុនការចេញសេចក្តីណែនាំនេះ។

សម្គាល់ៈ និយមន័យ **ទុនវិនិយោគ** សំដៅដល់តម្លៃវិនិយោគដែលបង្ហាញជារូបិយវត្ថុ ឬរូបិយបណ្ណបរទេស ដោយមិនរាប់បញ្ចូលតម្លៃដីធ្លី និងទុនបង្វិល។

ក្នុងករណីមិនអនុវត្តតាមសេចក្តីណែនាំនេះ គ.វ.ក./ក.អ.ក. នឹងចាត់វិធានការតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដែលអាចឈានដល់ការដកហូតការលើកទឹកចិត្តវិនិយោគ។

អាស្រ័យហេតុនេះ សូមលោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ដែលជាវិនិយោគិនក្នុងវិស័យកម្មន្តសាល មេត្តាចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

**ចម្លងជូនៈ**
- ខុទ្ទកាល័យ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ប្រធាន ក.អ.ក.
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក.អ.ក.
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល អនុប្រធានទី៣ ក.អ.ក.
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋាន : វិមានរដ្ឋាភិបាល តីរវិថីព្រះស៊ីសុវត្ថិ វត្តភ្នំ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥)២៣- ៧២៤ ៤៧៧ / ទូរសារ : (៨៥៥)២៣- ៩៨១ ២៥៧
Address : Government Palace, Sisowath Quay, Wat Phnom, Phnom Penh, Kingdom of Cambodia.
Tel : (855) 23-724 477 / Fax : (855) 23-981 257